អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះសាលាដំបូង**
**Trial Chamber**
**Chambre de première instance**

ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូងប្រកាសកាត់បន្ថយចំនួនថ្ងៃសវនាការប្រចាំសប្តាហ៍ក្នុងសំណុំរឿង ០០២/០១

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សូមជម្រាបជូនដំណឹងថា ចាប់ពីថ្ងៃ ច័ន្ទ ទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ តទៅ អង្គជំនុំជម្រះនឹងកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការរបស់ខ្លួន ដោយធ្វើសវនាការតែពីថ្ងៃច័ន្ទ ដល់ថ្ងៃពុធ ប៉ុណ្ណោះ សម្រាប់សប្តាហ៍នីមួយៗ។

ការិយាល័យជំនួយរដ្ឋបាលរបស់អង្គការសហប្រជាជាតិដល់តុលាការខ្មែរក្រហម (UNAKRT) បានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា ដោយសារបញ្ហាកង្វះថវិកា អង្គជំនុំជម្រះសាលាដំបូងពុំអាចជ្រើសរើសមន្ត្រីដើម្បីមកជំនួសកន្លែងមន្ត្រីច្បាប់អន្តរជាតិសំខាន់ៗមួយចំនួន និងបុគ្គលិកអន្តរជាតិដទៃទៀតបានឡើយ។ ចំនួនបុគ្គលិកអន្តរជាតិនាពេលបច្ចុប្បន្ននេះមានប្រហែលតែពាក់កណ្តាលប៉ុណ្ណោះនៃតារាងបញ្ជីបុគ្គលិកសរុបរបស់អង្គជំនុំជម្រះ-សាលាដំបូង ដែលបានអនុម័តរួចហើយនៅក្នុងគម្រោងថវិកាសម្រាប់ អ.វ.ត.ក។ អស់រយៈពេល ៣ ខែ មកហើយអង្គជំនុំជម្រះបានជូនដំណឹងម្តងហើយម្តងទៀតទៅផ្នែករដ្ឋបាលនៃ UNAKRT និងផ្នែកពាក់ព័ន្ធនៃអង្គការសហ-ប្រជាជាតិ (អ.ស.ប) អំពីការលំបាកដែលអង្គជំនុំជម្រះកំពុងប្រឈម ដោយសារពុំមានបុគ្គលិកគ្រប់គ្រាន់ដើម្បីបំពេញការងារឲ្យបានពេញលេញ និងមានប្រសិទ្ធភាព។ ជាការឆ្លើយតប អង្គជំនុំជម្រះទទួលបានការធានាថា បញ្ហាបុគ្គលិកនឹងត្រូវបានដោះស្រាយ ក៏ប៉ុន្តែរហូតមកទល់នឹងពេលនេះពុំទាន់មានដំណោះស្រាយជាស្ថាពរណាមួយឡើយ។

ដោយសារនាពេលបច្ចុប្បន្ននេះ ចៅក្រមមានពេលតែមួយថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍ ក្រៅពីថ្ងៃជំនុំជម្រះដើម្បីបំពេញកិច្ចការនានានោះ ជំនួយពីមន្ត្រីច្បាប់ និងបុគ្គលិកដទៃទៀតសម្រាប់ដំណើរការទាំងនៅក្នុង និងនៅក្រៅបន្ទប់សវនាការគឺជាការចាំបាច់។ មន្ត្រីរបស់អង្គជំនុំជម្រះសាលាដំបូងជាអ្នកបំពេញការងារបឋមសំខាន់ៗ តាមរយៈការរៀបចំបញ្ជីឈ្មោះសាក្សី និងការធ្វើសេចក្តីសង្ខេបជូនចៅក្រម រួមទាំងការកែសម្រួល និងការរៀបចំឯកសារស្ថាពរបន្ទាប់ពីចៅក្រមបានពិភាក្សាគ្នារួច។ ជាងនេះទៀត មន្ត្រីច្បាប់ជាអ្នករៀបចំសេចក្តីព្រាងដំបូងនៃសេចក្តីសម្រេចទាំង

អស់ ដោយផ្អែកតាមការណែនាំរបស់ចៅក្រម។ បុគ្គលិកទាំងនេះក៏បានជួយធ្វើការស្រាវជ្រាវលើបញ្ហាច្បាប់ស្មុគស្មាញដែលភាគីបានលើកឡើង តាមរយៈសារណាដោយផ្ទាល់មាត់ក្តី និងជាលាយលក្ខណ៍អក្សរក្តី រួមទាំងការឆ្លើយតបទៅនឹងការងាររដ្ឋបាលជាច្រើន ដែលចាំបាច់សម្រាប់ឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយរលូន។ យ៉ាងហោចណាស់ក៏តម្រូវឲ្យមានមន្ត្រីច្បាប់អន្តរជាតិមួយរូបដែរ ក្នុងបន្ទប់សវនាការក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី ដើម្បីផ្តល់ជំនួយដល់ចៅក្រម ដែលជាការចាំបាច់សម្រាប់ឲ្យចៅក្រមមានលទ្ធភាពចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ដែលជាញឹកញាប់គឺក្នុងពេលដែលសវនាការកំពុងតែប្រព្រឹត្តទៅ។

អង្គជំនុំជម្រះយល់អំពីភាពចាំបាច់នៃការធ្វើសវនាការឲ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន។ យ៉ាងណាមិញ ក្នុងអំឡុងពេលប៉ុន្មានខែកន្លងទៅនេះ អង្គជំនុំជម្រះបានខិតខំព្យាយាមបំពេញការងារជាមួយមន្ត្រីមួយចំនួនតូចដែលនៅសេសសល់ ប៉ុន្តែបន្ទុកការងារគឺស្ថិតក្នុងកម្រិតមួយ ដែលការខ្វះខាតចំនួនបុគ្គលិកនាពេលបច្ចុប្បន្នអាចនាំទៅដល់ការពន្យារពេលនៃការចេញសេចក្តីសម្រេច ហើយនឹងប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី។ ដើម្បីធានាបានថា អង្គជំនុំជម្រះសាលាដំបូងអាចឆ្លើយតបទៅនឹងសំណើនានារបស់ភាគីបានទាន់ពេលវេលា និងត្រៀមរៀបចំសម្រាប់ការស្តាប់សក្ខីកម្មនៅថ្ងៃខាងមុខរបស់សាក្សី និងអ្នកជំនាញដែលនៅសេសសល់នោះ ចៅក្រមត្រូវការពេលវេលាច្រើនជាងនេះនៅក្រៅបន្ទប់សវនាការដើម្បីបំពេញការងារត្រៀមរៀបចំនានា ដែលកាលពីពេលកន្លងទៅមានមន្ត្រីរបស់ខ្លួនជាអ្នកបំពេញ។

អាស្រ័យហេតុនេះ ទើបបានជាអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នាពេលកន្លងទៅថ្មីៗនេះប្រាប់ផ្នែកពាក់ព័ន្ធទាំងនោះថា នៅពេលពុំមានបុគ្គលិកគ្រប់គ្រាន់ដើម្បីជួយកិច្ចការរបស់អង្គជំនុំជម្រះទេនោះ អង្គជំនុំជម្រះពុំអាចបន្តធ្វើសវនាការចំនួន ០៤ ថ្ងៃក្នុងមួយសប្តាហ៍ទៀតបានឡើយ។ អង្គជំនុំជម្រះសោកស្តាយដែលថា ការកាត់បន្ថយចំនួនថ្ងៃសវនាការប្រចាំសប្តាហ៍នេះនឹងនាំឲ្យមានការអូសបន្លាយពេលវេលា ដែលចាំបាច់សម្រាប់បញ្ចប់សំណុំរឿង ០០២/០១ ដោយជៀសពុំរួច។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ប្រសិនបើបញ្ហាបុគ្គលិកមានភាពល្អប្រសើរនាពេលខាងមុខនោះ អង្គជំនុំជម្រះនឹងពិនិត្យមើលឡើងវិញអំពីចំនួនថ្ងៃដែលខ្លួនធ្វើសវនាការ។

ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**

មន្ត្រីទំនាក់ទំនងផ្នែកច្បាប់

ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ០២៣

ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦១ ៦៦៩ –

លេខភ្ជាប់បន្ត៖ ៦១៦៩

សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**

មន្ត្រីនាំពាក្យ អ.វ.ត.ក

ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh